# សៀវភៅមគ្គុទេសក៍

## ស្តីពី

## ការប្រើប្រាស់វេបផតថល និង កម្មវិធីទូរសព្ទដៃ ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ



# មាតិកា


- ១. ហេតុអ្វីត្រូវចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ? ០១
- ២. នរណាអាចចុះឈ្មោះបាន? ០១
- ៣. មធ្យោបាយនៃការចុះឈ្មោះ ០២
  - ៣.១. ឯកសារតម្រូវសម្រាប់ការចុះឈ្មោះ ០៣
  - ៣.២. របៀបចុះឈ្មោះតាមកម្មវិធីទូរសព្ទដៃ Cam-IE ០៤
  - ៣.៣. របៀបចុះឈ្មោះតាមវេបផតថល ១០
  - ៣.៤. របៀបចុះឈ្មោះតាមភ្នាក់ងារចុះឈ្មោះ ១៦
- ៤. ការទទួលបានវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ ១៨
- ៥. មុខងារផ្សេងៗ ២០
  - ៥.១. កម្មវិធីទូរសព្ទដៃ Cam-IE ២០
    - ៥.១.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត ២០
    - ៥.១.២. មុខងារទាញយកវិញ្ញាបនបត្រ ២២
    - ៥.១.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់ ២៣
    - ៥.១.៤. ទំព័រដើម ២៥
    - ៥.១.៥. ជំនួយ ២៥
    - ៥.១.៦. ដំណឹង ២៦
    - ៥.១.៧. ការកំណត់ ២៦
  - ៥.២. វេបផតថល ២៧
    - ៥.២.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត ២៧
    - ៥.២.២. មុខងារទាញយកវិញ្ញាបនបត្រ ៣០
    - ៥.២.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់ ៣១
    - ៥.២.៤. ទំព័រដើម ៣៤
    - ៥.២.៥. ជំនួយ ៣៤
    - ៥.២.៦. ដំណឹង ៣៥
    - ៥.២.៧. ការកំណត់ ៣៥

**ហាមថតចម្លង**
រក្សាសិទ្ធិឆ្នាំ ២០២៤ ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល

**រក្សាសិទ្ធិគ្រប់យ៉ាង**
បោះពុម្ពផ្សាយដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល
បោះពុម្ពផ្សព្វផ្សាយលើកទី ១ នៅឆ្នាំ ២០២៤

## ✣ ១. ហេតុអ្វីត្រូវចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ?

**ចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

ដើម្បីមានលទ្ធភាពទទួលបានការលើកទឹកចិត្តនិង ការថែបំប៉នផ្សេងៗ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ✣ ២. នរណាអាចចុះឈ្មោះបាន?

### ១ កម្មករ និយោជិតនៃសហគ្រាសធុនមីក្រូ

សំដៅដល់ជនគ្រប់ភេទ ដែលបានចុះកិច្ចសន្យាធ្វើការយកកម្រៃ ក្រោមការដឹកនាំនិងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀតជារូបវន្តបុគ្គល ឬ នីតិបុគ្គលជាសាធារណៈ ឬ ឯកជន។

### ២ កម្មករ និយោជិតម្តងម្កាល

សំដៅដល់ជនដែលចុះកិច្ចសន្យាធ្វើការមួយជាប្រាកដតាមធម្មតាត្រូវតែឱ្យហើយក្នុងរយៈពេលយ៉ាងខ្លី និងធ្វើការមួយពេលៗ ធ្វើឈប់ៗ និងធ្វើមួយរដូវៗ។

### ៣ សហគ្រាសធុនមីក្រូ

សំដៅដល់សហគ្រាស អាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំក្រោម ៦២២៥០ ដុល្លារអាម៉េរិក ឬ មានចំនួនកម្មករនិយោជិតក្រោម ៥នាក់។

### ៤ បុគ្គលស្វ័យនិយោជន៍

សំដៅដល់ជនដែលប្រកបការងារ ឬ មុខរបររកចំណូលផ្ទាល់ខ្លួន ដោយមិនពាក់ព័ន្ធនឹងប្រាក់ឈ្នួល ឬ ប្រាក់បៀវត្សដែលផ្តល់ដោយនិយោជក ឬ រដ្ឋ តាមកិច្ចសន្យាការងារ ហើយក៏មិនមានប្រើប្រាស់ កម្មករ និយោជិត នៅក្នុងសកម្មភាពការងារ ឬ មុខរបររបស់ខ្លួន។

## ✣ ៣. មធ្យោបាយនៃការចុះឈ្មោះ

ការចុះឈ្មោះមានច្រើនមធ្យោបាយ ហើយអាចសម្រេចទៅបាន ក្នុងរយៈពេលត្រឹមតែ ៥ នាទីតែប៉ុណ្ណោះ។

កម្មវិធីទូរសព្ទដៃ Cam-IE ឬ វេបផតថល
ដោយចូលទៅកាន់ គេហទំព័រ
**www.informal.digitaleconomy.gov.kh**



ចុះឈ្មោះតាមរយៈ

**ភ្នាក់ងារចុះឈ្មោះ**




ធនាគារអភិវឌ្ឍជនបទ និង កសិកម្ម



ធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា



ភ្នាក់ងារ និង សាខាធនាគារវីង



ធនាគារអេស៊ីលីដា



ធនាគារវឌ្ឍនៈអាស៊ីចំកាត់ ABA

## ៣.១. ឯកសារតម្រូវសម្រាប់ការចុះឈ្មោះ

### កម្មករ និយោជិតនៃសហគ្រាសធុនមីក្រូ
### កម្មករ និយោជិតម្តងម្កាល បុគ្គលស្វ័យនិយោជន៍

ព័ត៌មានអំពីអត្តសញ្ញាណ, ព័ត៌មានសេដ្ឋកិច្ច, ព័ត៌មានអប់រំ និង ព័ត៌មានផ្សេងៗ



រូបថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម



រូបថតផ្ទៃមុខជាមួយទីតាំងអាជីវកម្ម



រូបថតសកម្មភាពអាជីវកម្ម



រូបថតផ្ទៃមុខ



### សហគ្រាសធុនមីក្រូ

ព័ត៌មានអំពីអត្តសញ្ញាណរបស់ម្ចាស់, ព័ត៌មានសេដ្ឋកិច្ច, ព័ត៌មានអប់រំ និង ព័ត៌មានផ្សេងៗ



រូបថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើមរបស់ម្ចាស់



រូបថតផ្ទៃមុខជាមួយទីតាំងអាជីវកម្ម



រូបថតសកម្មភាពអាជីវកម្ម



រូបថតផ្ទៃមុខ



## ៣.២. របៀបចុះឈ្មោះតាមកម្មវិធីទូរសព្ទដៃ

ចូលក្នុង App Store ឬ Google Play store រួចទាញយកកម្មវិធីទូរសព្ទដៃ **Cam-IE**។



# កម្មវិធីទូរសព្ទ

# Cam-IE

Download on the App Store

GET IT ON Google Play



**១.** ចូលទៅកាន់កម្មវិធីទូរសព្ទដៃ Cam-IE។




**២.** ចុច **“បន្ទាប់”** ដើម្បីបង្កើតគណនីប្រើប្រាស់ថ្មី។




**៣.** បញ្ចូលលេខទូរសព្ទ រួចបង្កើតកូដសម្ងាត់ និង បញ្ជាក់កូដសម្ងាត់របស់លោកអ្នក។ កូដសម្ងាត់ត្រូវមានយ៉ាងតិច ៦ តួអក្សរ ដែលតម្រូវឱ្យមានអក្សរតូច អក្សរធំ និង លេខ។

**៤.** អានលក្ខខណ្ឌប្រើប្រាស់ និង គោលការណ៍ឯកជនភាព រួចចុចប៊ូតុង ☑ នៅលើប្រអប់ដើម្បីអះអាងថាពិតជាបានអាន និង យល់ព្រមលើលក្ខខណ្ឌប្រើប្រាស់ និង គោលការណ៍ឯកជនភាព រួចចុចប៊ូតុង **“បង្កើតគណនីថ្មី”**។

**៥.** បញ្ចូលលេខកូដ (One - Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរសព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទីនោះទេ ចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។





**៦.** ចុច **“ថតរូប”** ដើម្បីថតរូបអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើមរបស់លោកអ្នក។



**៧.** ថតរូបឱ្យឃើញផ្ទៃមុខរបស់លោកអ្នក។ ហាមពាក់ម៉ាស់ មួក និង/ឬ វ៉ែនតា ក្នុងអំឡុងពេលថតរូប និង ជៀសវាងរូបភាពឃើញមុខមិនច្បាស់ ឬ មានអ្នកផ្សេងនៅផ្នែកខាងក្រោយនៃរូបថត។

**៨.** ផ្ទៀងផ្ទាត់ព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលត្រូវបានបំពេញដោយស្វ័យប្រវត្តិ។ កែតម្រូវប្រសិនបើមានខុស រួចចុច **“បន្ទាប់”**។




**៩.** ចុចលើសញ្ញាបូក ⊕ រួចជ្រើសរើសកម្មករ-និយោជិត, សហគ្រាសធុនមីក្រូ ឬ បុគ្គលស្វ័យនិយោជន៍។



**១០.** វាយបញ្ចូលប្រភេទអាជីវកម្ម មុខរបរ ឬ ការងារ បន្ទាប់មកបំពេញទម្រង់បែបបទដែលនៅសេសសល់ឲ្យបានត្រឹមត្រូវ រួចចុច**"បន្ទាប់"**។




ក្នុងករណីដែលលោកអ្នកប្រកបអាជីវកម្មមុខរបរ ឬ ការងារផ្សេងទៀតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចុចប៊ូតុង **"រក្សាទុក និង បន្ថែមអាជីវកម្ម/មុខរបរ/ការងារថ្មី"** រួចជ្រើសរើសបំពេញព័ត៌មានដែលនៅសេសសល់ឱ្យបានត្រឹមត្រូវជាការស្រេច។

**១១.** ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។

**១២.** អានលក្ខខណ្ឌ រួចចុចប៊ូតុង ☑ នៅក្នុងប្រអប់ដើម្បីអះអាងថាលោកអ្នកពិតជាបានផ្ដល់ព័ត៌មានពិតប្រាកដមែន និង ចុះឈ្មោះដោយស្ម័គ្រចិត្តមិនមានការបង្ខិតបង្ខំ។




**១៣.** ចុចប៊ូតុង **"ចុះឈ្មោះ"** ជាការស្រេច។




# លោកអ្នកនឹងអាចចូលទៅ (Log In)

ក្នុងកម្មវិធីទូរសព្ទដៃ ដើម្បីទទួលបានស្ថានភាពចុងក្រោយនៃការស្នើសុំចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

សូមរង់ចាំយ៉ាងយូរ **១ ថ្ងៃ នៃថ្ងៃធ្វើការ** ដើម្បីឱ្យមន្ត្រីមានសមត្ថកិច្ច ផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។

## ៣.៣. របៀបចុះឈ្មោះតាមវេបផតថល

**១.** ចូលទៅកាន់តំណភ្ជាប់ www.informal.digitaleconomy.gov.kh
ឬ ស្កេន QR កូដ រួចចុច **“ចុះឈ្មោះឥឡូវនេះ”** ។

ស្កេនតាមរយៈ
**QR កូដនេះ**



**២.** ចុចប៊ូតុង **“បង្កើតគណនីថ្មី”** ដើម្បីបង្កើតគណនីប្រើប្រាស់ថ្មី។



**៣.** បញ្ចូលលេខទូរសព្ទ រួចបង្កើតកូដសម្ងាត់ និង បញ្ជាក់កូដសម្ងាត់របស់លោកអ្នក។ កូដសម្ងាត់ត្រូវមានយ៉ាងតិច ៦ តួអក្សរ ដែលតម្រូវឱ្យមានអក្សរតូច អក្សរធំ និង លេខ។

**៤.** អានលក្ខខណ្ឌប្រើប្រាស់ គោលការណ៍ឯកជនភាព រួចចុចប៊ូតុង ☑ នៅលើប្រអប់ដើម្បីអះអាងថាពិតជាបានអាន និង យល់ព្រមលើលក្ខខណ្ឌប្រើប្រាស់ និង គោលការណ៍ឯកជនភាព រួចចុចប៊ូតុង **“បង្កើតគណនីថ្មី”**។



**៥.** បញ្ចូលលេខកូដ (One-Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរសព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទីនោះទេ ចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។




**៦.** បញ្ចូលរូបថតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើមរបស់លោកអ្នកជាទម្រង់ PNG, JPG, ឬ JPEG។



**៧.** ចុច **“បញ្ចូល”** ដើម្បីបញ្ចូលរូបថតផ្ទៃមុខរបស់លោកអ្នក។



**៨.** ផ្ទៀងផ្ទាត់ព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលត្រូវបានបំពេញដោយស្វ័យប្រវត្តិ។ កែតម្រូវប្រសិនបើមានខុស រួចចុច **“បន្ទាប់”**។



**៩.** ជ្រើសរើសកម្មករ-និយោជិត, សហគ្រាសធុនមីក្រូ ឬ បុគ្គលស្វ័យនិយោជន៍។




**១០.** វាយបញ្ចូលប្រភេទអាជីវកម្ម មុខរបរ ឬ ការងារ បន្ទាប់មកបំពេញទម្រង់បែបបទដែលនៅសេសសល់ឱ្យបានត្រឹមត្រូវ រួចចុច **“រក្សាទុក”**។

ក្នុងករណីដែលលោកអ្នកប្រកបអាជីវកម្ម មុខរបរ ឬ ការងារផ្សេងទៀតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចុចប៊ូតុង **“បន្ថែម”** រួចជ្រើសរើសបំពេញព័ត៌មានដែលនៅសេសសល់ឱ្យបានត្រឹមត្រូវជាការស្រេច។



**១១.** ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។
**១២.** អានលក្ខខណ្ឌ រួចចុចប៊ូតុង ☑ នៅក្នុងប្រអប់ដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន និង ចុះឈ្មោះដោយស្ម័គ្រចិត្ត មិនមានការបង្ខិតបង្ខំ។
**១៣.** ចុចប៊ូតុង **"ចុះឈ្មោះ"** ជាការស្រេច។



## ៣.៤. របៀបចុះឈ្មោះតាមភ្នាក់ងារចុះឈ្មោះ

ក្នុងករណីលោកអ្នកមិនអាចចុះឈ្មោះដោយខ្លួនឯង តាមរយៈកម្មវិធីទូរសព្ទដៃ និង វេបផតថលបាន លោកអ្នកក៏អាចចុះឈ្មោះបានតាមភ្នាក់ងារចុះឈ្មោះរបស់យើងខ្ញុំ ដែលមានដូចជា សាខាធនាគារសហគ្រាសធុនតូច និង មធ្យមកម្ពុជា, ធនាគារអភិវឌ្ឍជនបទ និង កសិកម្ម, ធនាគារវីង, ធនាគារអេស៊ីលីដា និង ធនាគារ ABA។

### ឯកសារតម្រូវសម្រាប់ការចុះឈ្មោះ



អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម



ករណីចុះឈ្មោះជាកម្មករ និយោជិតនៃសហគ្រាសធុនមីក្រូ ឬ កម្មករ និយោជិតម្តងម្កាល ឬ បុគ្គលស្វ័យនិយោជន៍ តម្រូវឱ្យមានរូបថតផ្ទៃមុខ រូបថតផ្ទៃមុខជាមួយទីតាំងអាជីវកម្ម និង រូបថតសកម្មភាពអាជីវកម្ម ដែលមានស្រាប់ក្នុងទូរសព្ទដៃរបស់លោកអ្នក។



ករណីចុះឈ្មោះជាសហគ្រាសធុនមីក្រូ តម្រូវឱ្យមានរូបថតផ្ទៃមុខ រូបថតផ្ទៃមុខម្ចាស់ជាមួយទីតាំងអាជីវកម្ម និង រូបថតសកម្មភាពអាជីវកម្ម ដែលមានស្រាប់ក្នុងទូរសព្ទដៃរបស់លោកអ្នក។

សូមបញ្ចូលលេខទូរសព្ទដៃដែលបានចុះឈ្មោះ និង បង្កើតកូដសម្ងាត់ រួចបញ្ជាក់កូដសម្ងាត់សម្រាប់បង្កើតគណនីប្រើប្រាស់ ដើម្បីលោកអ្នកអាចតាមដានស្ថានភាពនៃពាក្យស្នើសុំតាមរយៈការចូលទៅ (Log In) កាន់វេបផតថល ឬ កម្មវិធីទូរសព្ទដៃ។ សូមស្នើសុំជំនួយពីភ្នាក់ងារចុះឈ្មោះរបស់យើងខ្ញុំ ក្នុងករណីលោកអ្នកមិនអាច ឬ មិនមានមធ្យោបាយក្នុងការតាមដានពាក្យស្នើសុំដូចបានរៀបរាប់ខាងលើ។

# សូមចូលទៅកាន់

**www.informal.digitaleconomy.gov.kh**

ដើម្បីស្វែងរកទីតាំងភ្នាក់ងារចុះឈ្មោះដែលនៅជិតលោកអ្នកបំផុត។



# ✦ ៤. ការទទួលបានវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្រោយការចុះឈ្មោះជាអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធតាមរយៈមធ្យោបាយណាមួយខាងលើ បានជោគជ័យ និង ទទួលបានការអនុម័តពីមន្ត្រីជំនាញមានសមត្ថកិច្ច, លោកអ្នកនឹងទទួលបានវិញ្ញាបនបត្រចុះឈ្មោះ អ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

នៅពេលចូល (Log In) ទៅកាន់វេបផតថល ឬ កម្មវិធីទូរសព្ទដៃ, លោកអ្នកអាចទាញយកនូវវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងទម្រង់ឌីជីថល ដើម្បីមករក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកណាមួយរបស់លោកអ្នកសម្រាប់ប្រើប្រាស់ជាផ្លូវការ។

វិញ្ញាបនបត្រឌីជីថលនេះមានតម្លៃសមមូលនឹងវិញ្ញាបនបត្ររូបវ័ន្ត ហើយក្នុងករណីបាត់បង់ លោកអ្នកនៅតែអាចទាញយកវិញ្ញាបនបត្រនៅពេលណាក៏បាន គ្រប់ទីកន្លែង តាមរយៈផតថល ឬ កម្មវិធីទូរស័ព្ទដៃ (សូមអានផ្នែក ៥.១.២. និង ផ្នែក ៥.២.២. សម្រាប់របៀបនៃការទាញយកវិញ្ញាបនបត្រ)។



ចុះឈ្មោះតាមរយៈថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, លោកអ្នកនឹងអាចទទួលបាននូវការថែបំប៉ន និង អត្ថប្រយោជន៍ផ្សេងៗ។

## ដើម្បីទទួលបានព័ត៌មានពីអត្ថប្រយោជន៍ផ្សេងៗ

**សូមតាមដានយើងតាមរយៈ:**

- ១២៦៤
- ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ
- Cam-IE
- ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

គេហទំព័រ



## ✦ ៥. មុខងារផ្សេងៗ

### • ៥.១. កម្មវិធីទូរសព្ទដៃ Cam-IE

#### ៥.១.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត

ក្នុងករណីព័ត៌មានដែលបានដាក់ស្នើសុំមិនត្រឹមត្រូវ ឬ ត្រូវការកែតម្រូវ, ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានបញ្ជូនត្រលប់មកវិញ។ ក្នុងករណីនេះ, សូមចូលទៅកាន់កម្មវិធីទូរសព្ទដៃ រួចធ្វើតាមការណែនាំខាងក្រោម៖









**១.** ពិនិត្យលើមូលហេតុបញ្ជូនត្រលប់ រួចចុច **“ពិនិត្យឡើងវិញ”**។
**២.** កែតម្រូវព័ត៌មានអត្តសញ្ញាណ ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។
**៣.** កែតម្រូវព័ត៌មានសេដ្ឋកិច្ច និង ព័ត៌មានអប់រំ ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។




៤. ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។




៥. អានលក្ខខណ្ឌ រួចចុចប៊ូតុង ☑នៅក្នុងប្រអប់ដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន និងចុះឈ្មោះដោយស្ម័គ្រចិត្ត មិនមានការបង្ខិតបង្ខំ។

៦. ចុចប៊ូតុង **“ចុះឈ្មោះម្តងទៀត”** ជាការស្រេច។

សូមរង់ចាំយ៉ាងយូរ ១ ថ្ងៃ នៃថ្ងៃធ្វើការដើម្បីមន្ត្រីមានសមត្ថកិច្ចផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។

# ៥.១.២. មុខងារទាញយកវិញ្ញាបនបត្រ

## ដើម្បីទាញយកវិញ្ញាបនបត្រ ទម្រង់ឌីជីថលក្នុងករណីអនុម័ត

ចុចសញ្ញា នោះលោកអ្នកអាចទាញយកវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធសម្រាប់ប្រើប្រាស់ជាផ្លូវការ។



## ៥.១.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់

- ករណីប្តូរកូដសម្ងាត់



**១.** ដើម្បីប្តូរកូដសម្ងាត់ ចុច **"ការកំណត់"** រួចចុច **"ប្តូរកូដសម្ងាត់"**។



**២.** បញ្ចូលលេខទូរសព្ទដែលធ្លាប់បានប្រើប្រាស់សម្រាប់ការស្នើសុំ រួចបង្កើតកូដសម្ងាត់ថ្មី រួចបញ្ចូលកូដសម្ងាត់ម្តងទៀតដើម្បីបញ្ជាក់ភាពត្រឹមត្រូវ។ កូដសម្ងាត់ត្រូវមានយ៉ាងតិច ៦ តួអក្សរ ដែលតម្រូវឱ្យមានអក្សរតូច អក្សរធំ និងលេខ រួចចុច **"បន្ទាប់"**។



**៣.** បញ្ចូលលេខកូដ (One - Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរសព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទីនោះទេ ចុច **"ផ្ញើឡើងវិញ"** ដើម្បីទទួលបានលេខកូដថ្មី។ នោះកូដសម្ងាត់ត្រូវបានប្តូរដោយជោគជ័យ។

## ករណីភ្លេចកូដសម្ងាត់

**១.** ក្នុងករណីភ្លេចកូដសម្ងាត់ ចុច **“ចូលប្រើប្រាស់”** រួចចុច **“ភ្លេចកូដសម្ងាត់”**។



**២.** បញ្ចូលលេខទូរសព្ទដែលធ្លាប់បានប្រើប្រាស់សម្រាប់ការស្នើសុំ រួចបញ្ចូលលេខកូដ (One -Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទី នោះទេ ចុច **“ផ្ញើឡើងវិញ”** ដើម្បីទទួលបានលេខកូដថ្មី។



**៣.** បង្កើតកូដសម្ងាត់ថ្មី រួចបញ្ចូលកូដសម្ងាត់ម្តងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ។ អានលក្ខខណ្ឌប្រើប្រាស់ និង គោលការណ៍ឯកជនភាព រួចចុចប៊ូតុង ☑ នៅក្នុងប្រអប់ដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន។ ចុចប៊ូតុង **“រួចរាល់”** នោះកូដសម្ងាត់បានប្តូរដោយជោគជ័យ។



## ៥.១.៤. ទំព័រដើម



នៅលើទំព័រដើមនៃកម្មវិធីទូរសព្ទដៃ, លោកអ្នកនឹងអាចតាមដានស្ថានភាពនៃពាក្យស្នើសុំចុះឈ្មោះរបស់លោកអ្នក ពិនិត្យព័ត៌មានផ្ទាល់ខ្លួន តាមដានសេចក្ដីជូនដំណឹង និង ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ៥.១.៥. ជំនួយ

- ចុច “ជំនួយ” នៅផ្នែកខាងក្រោមនៃកម្មវិធីទូរសព្ទដៃ ដើម្បីស្វែងរកមធ្យោបាយទាក់ទងមកកាន់ក្រុមការងារ ក្នុងករណីមានចម្ងល់ ឬ បញ្ហាផ្សេងៗ។



## ៥.១.៦. ដំណឹង




- ចុច **“ដំណឹង”** នៅផ្នែកខាងក្រោមនៃកម្មវិធីទូរសព្ទដៃ ដើម្បីទទួលបានសេចក្តីជូនដំណឹងផ្សេងៗ។

## ៥.១.៧. ការកំណត់




- ចុច **“ការកំណត់”** នៅផ្នែកខាងក្រោមនៃកម្មវិធីទូរសព្ទដៃ ដើម្បីស្វែងរកព័ត៌មានអត្តសញ្ញាណរបស់លោកអ្នកដែលបានចុះឈ្មោះជាមួយយើងខ្ញុំ និង លក្ខខណ្ឌប្រើប្រាស់ និង គោលការណ៍ឯកជនភាព។
- ចុច **“ចាកចេញ”** ដើម្បីចាកចេញ (Log Out) ពីគណនីរបស់លោកអ្នក។

## ៥.២. វេបផតថល

### ៥.២.១. មុខងារបញ្ជូនត្រលប់ និង ដាក់ស្នើម្តងទៀត

ក្នុងករណីព័ត៌មានដែលបានដាក់ស្នើសុំមិនត្រឹមត្រូវ ឬ ត្រូវការកែតម្រូវ, ពាក្យស្នើសុំរបស់លោកអ្នកនឹងត្រូវបានបញ្ជូនត្រលប់មកវិញ។ ក្នុងករណីនេះ, សូមចូលទៅកាន់វេបផតថល រួចធ្វើតាមការណែនាំខាងក្រោម៖

**១.** ពិនិត្យលើមូលហេតុបញ្ជូនត្រលប់ រួចចុច **“ពិនិត្យឡើងវិញ”**។



**២.** កែតម្រូវព័ត៌មានអំពីអត្តសញ្ញាណ និង ព័ត៌មានអប់រំ ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។



**៣.** កែតម្រូវព័ត៌មានសេដ្ឋកិច្ច ប្រសិនបើបំពេញខុស រួចចុច **“បន្ទាប់”**។



**៤.** ផ្ទៀងផ្ទាត់ព័ត៌មានដែលបានបំពេញសារឡើងវិញ។

**៥.** អានលក្ខខណ្ឌ រួចចុចប៊ូតុង ☑ នៅក្នុងប្រអប់ដើម្បីអះអាងថាលោកអ្នកពិតជាបានផ្តល់ព័ត៌មានពិតប្រាកដមែន និង ចុះឈ្មោះដោយស្ម័គ្រចិត្ត មិនមានការបង្ខិតបង្ខំ។

**៦.** ចុចប៊ូតុង **“ចុះឈ្មោះម្តងទៀត”** ជាការស្រេច។



សូមរង់ចាំយ៉ាងយូរ ១ ថ្ងៃ នៃថ្ងៃធ្វើការដើម្បីមន្ត្រីមានសមត្ថកិច្ចផ្ទៀងផ្ទាត់ និងត្រួតពិនិត្យពាក្យស្នើសុំរបស់លោកអ្នក។

## ៥.២.២. មុខងារទាញយកវិញ្ញាបនបត្រ

**១.** ដើម្បីទាញយកវិញ្ញាបនបត្រទម្រង់ឌីជីថលក្នុងករណីអនុម័ត ចុច **"វិញ្ញាបនបត្រ"** នោះលោកអ្នកអាចទាញយកវិញ្ញាបនបត្រចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ សម្រាប់ប្រើប្រាស់ជាផ្លូវការ។



**២.** ចុច រួចចុច **"ទាញយក"** នោះលោកអ្នកអាចទាញយកវិញ្ញាបនបត្របានដោយជោគជ័យ។



## ៥.២.៣. មុខងារផ្លាស់ប្តូរកូដសម្ងាត់

### ◆ ករណីប្តូរកូដសម្ងាត់

• ចុចលើ **“រូបភាព”** របស់លោកអ្នក នៅផ្នែកខាងស្តាំ ខាងលើនៃវេបផតថល រួចចុច **“ការកំណត់គណនី”**។



• ចុច ✎ រួចបញ្ចូលលេខទូរសព្ទធ្លាប់បានប្រើប្រាស់សម្រាប់ការស្នើសុំ បន្ទាប់មកបង្កើតកូដសម្ងាត់ថ្មី និង បញ្ជាក់កូដសម្ងាត់ថ្មី រួចចុច **“បន្ទាប់”** ជាការស្រេច។



## ករណីភ្លេចកូដសម្ងាត់

**១.** ក្នុងករណីភ្លេចកូដសម្ងាត់ ចុច **“ចូលគណនី”** រួចចុច **“ភ្លេចកូដសម្ងាត់”**។




**២.** បញ្ចូលលេខទូរសព្ទដៃដែលធ្លាប់បានប្រើប្រាស់សម្រាប់ការស្នើសុំ បង្កើតកូដសម្ងាត់ថ្មី និង បញ្ចូលកូដសម្ងាត់ម្តងទៀត ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ រួចចុចប៊ូតុង **“ផ្ញើលេខកូដ”**។



**៣.** បញ្ចូលលេខកូដ (One-Time Passcode – OTP) ចំនួន ៦ ខ្ទង់ ដែលបានផ្ញើទៅកាន់លេខទូរស័ព្ទ។ ប្រសិនបើពុំទទួលបានលេខកូដ ៦ខ្ទង់ ពីប្រព័ន្ធក្នុងរយៈពេល ៦០ វិនាទីនោះទេ ចុច **"ផ្ញើឡើងវិញ"**។ ដើម្បីទទួលបានលេខកូដថ្មី។ ចុចប៊ូតុង **"ផ្ទៀងផ្ទាត់"** នោះកូដសម្ងាត់បានប្តូរដោយជោគជ័យ។



## ៥.២.៤. ទំព័រដើម

ទំព័រដើមនៃវេបផតថល, លោកអ្នកនឹងអាចតាមដានស្ថានភាពនៃពាក្យស្នើសុំចុះឈ្មោះរបស់លោកអ្នក ពិនិត្យព័ត៌មានផ្ទាល់ខ្លួន តាមដានសេចក្ដីជូនដំណឹង និង ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។



## ៥.២.៥. ជំនួយ

- ចុចលើ "រូបភាព" របស់លោកអ្នក នៅផ្នែកខាងស្ដាំ ខាងលើនៃវេបផតថល រួចចុច "ជំនួយ" ដើម្បីស្វែងរកមធ្យោបាយទាក់ទងមកកាន់ក្រុមការងារ ក្នុងករណីមានចម្ងល់ ឬ បញ្ហាផ្សេងៗ។



## ៥.២.៦. ដំណឹង

- ចុច 🔔 នៅផ្នែកខាងស្តាំ ខាងលើនៃវេបផតថល, ដើម្បីទទួលបានសេចក្តីជូនដំណឹង និង ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។



## ៥.២.៧. ការកំណត់

- ចុចលើរូបរបស់លោកអ្នក នៅផ្នែកខាងស្តាំ ខាងលើនៃផតថល រួចចុច **"ចាកចេញ"** ដើម្បីចាកចេញ **(Log Out)** ពីគណនីរបស់លោកអ្នក។



## អភិវឌ្ឍ និង រៀបចំដោយ

## សហការជាមួយ

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់៖


ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

១២៦៤

ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

Cam-IE

www.informal.digitaleconomy.gov.kh